00867262

E236/3/corr-1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-Dec-2012, 15:42
CMS/CFO: Uch Arun

# សំណើសុំការកែតម្រូវ

**សំណុំរឿងលេខ៖** 002/19-09-2007-ECCC/TC

| កែលើឯកសារលេខ៖ | ERN(s): | កាលបរិច្ឆេទ៖ | ប្រភេទកំណែ៖ |
|---|---|---|---|
| E236/3 | 00866793-00866796 | 6-12-2012 | ☐ កែលើឯកសារដើម<br>☒ កែលើឯកសារបកប្រែ<br>☐ រៀបចំចាត់ថ្នាក់ឡើងវិញ |

| មូលហេតុនៃការកែតម្រូវ៖ |
|---|
| សូមកែពាក្យ ឆ្នាំ២០១២ ទៅជា ឆ្នាំ២០០៧ |

| សេចក្តីលម្អិតនៃការកែតម្រូវ៖ |
|---|
| ការកែតម្រូវឯកសារនេះនៅត្រង់កថាខណ្ឌទី២ ERN ជាភាសាខ្មែរ 00866795 |

ស្នើដោយ៖ការិយាល័យសហព្រះរាជអាជ្ញា ហត្ថលេខា៖

Phann Sochea

បានទទួលការឯកភាពពីក្រឡាបញ្ជី(ចំពោះឯកសារដើម)៖ ហត្ថលេខា៖

បានទទួលការឯកភាពពីអង្គភាពបកប្រែភាសា(ចំពោះការបកប្រែ)៖ ហត្ថលេខា៖

00867263

E236/3/Corr-1



១. អនុលោមតាម វិធាន៨៧(៤), ៥៣(៤) និង ២១(១) នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាសុំការអនុញ្ញាតដើម្បីដាក់ទៅក្នុងសំណុំរឿងនូវ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដោយសង្ខេបមួយ ដែលបានធ្វើឡើងជាមួយសាក្សី TCW-247 នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៧ (កំណត់ហេតុស្តាប់ចម្លើយសាក្សី)[1]។ ឯកសារនេះមាននៅក្នុងប្រព័ន្ធគ្រប់គ្រងឯកសារ Database របស់សហព្រះរាជអាជ្ញា ដែលជាផ្នែកមួយនៃការត្រៀមរៀបចំសម្រាប់ការសួរដេញដោលសាក្សីរូបនេះ។

២. បទសម្ភាសន៍នេះដែលបានធ្វើឡើងកាលពីថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៣ គឺជាផ្នែកនៃស៊ើបអង្កេតដែលបានធ្វើឡើងដោយសហព្រះរាជអាជ្ញា ក្នុងរយៈពេលនៃកិច្ចស៊ើបសួរបឋមរបស់ខ្លួននៅក្នុងសំណុំរឿងនេះ។ កំណត់ហេតុស្តាប់ចម្លើយសាក្សីនេះមានតែជាភាសាអង់គ្លេសប៉ុណ្ណោះ ប៉ុន្តែវាមានមិនលើសពីពីរទំព័រទេ។ គេគ្មានកំណត់ហេតុណាផ្សេងទៀតនៃការស្តាប់ចម្លើយនេះទេ។

Deleted: ១២

៣. ទោះបីជា វិធានផ្ទៃក្នុងរបស់ អវតក មិនបានចែងច្បាស់ៗតម្រូវឱ្យសហព្រះរាជអាជ្ញាបង្ហាញជូននូវរាល់ចម្លើយពីមុនៗទាំងអស់របស់សាក្សីនានា ដែលអង្គជំនុំជម្រះសាលាដំបូងបានកោះហៅដើម្បីឱ្យមកផ្តល់សក្ខីកម្មនោះក្តី ក៏សហព្រះរាជអាជ្ញាបានប្រកាន់នូវទស្សនៈយល់ឃើញថា ការបង្ហាញជូនបែបនេះគោងតែមានការប្រុងប្រយ័ត្ន និងឱ្យស្របទៅតាមបទដ្ឋានអន្តរជាតិ[2] ។ ក្នុងការឆ្លើយតបទៅនឹងសំណើសុំការណែនាំទាក់ទងទៅនឹងចម្លើយនានាដែលចាត់ទុកជាការសំងាត់បំផុត ដែលបានផ្តល់ឱ្យដោយសាក្សីដែលមានសក្តានុពលនានានៅក្នុងពេលសវនាការលើសំណុំរឿងផ្សេងទៀត អង្គជំនុំជម្រះបានសំរេចថា ការបង្ហាញជូននូវចម្លើយសាក្សីទាំងនេះ (ជាលើកដំបូងជូនអង្គជំនុំជម្រះ ) គឺជាការនាំមកនូវផលប្រយោជន៍ដល់ការបញ្ជាក់ពីការពិត[3] ហើយដែលបន្ទាប់មកទៀតបានត្រៀមរៀបចំឱ្យមានជាស្រេចសំរាប់ផ្តល់ជូនដល់គ្រប់ភាគីទាំងអស់[4]។

---

[1] ឧបសម្ព័ន្ធសម្ងាត់ ក - ERN 00089733-00089734។

[2] ឯកសារលេខ E233/1 សំណើរបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងស្តីពីកំណត់ហេតុនៃការធ្វើសម្ភាសន៍សាក្សី TCW-428 របស់ មជ្ឈមណ្ឌលឯកសារកម្ពុជា ចុះថ្ងៃទី២៥ កញ្ញា ២០១២,ឯកសារលេខ E233/1 ។ ឯកសារលេខ E127 ការបង្ហាញជូនអង្គជំនុំជម្រះសាលាដំបូង របស់សហព្រះរាជអាជ្ញាអន្តរជាតិនូវកំណត់ហេតុ នៃការធ្វើសម្ភាសន៍សាក្សីនៃសំណុំរឿងលេខ០០២ នៅក្នុងសំណុំរឿងលេខ០០៣ និង០០៤ ដោយមានឧបសម្ព័ន្ធ ក ដែលចាត់ទុកជាការសំងាត់បំផុត ភ្ជាប់មកជាមួយផង, ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០១១, កថាខណ្ឌទី១២ ។ ការដែលតម្រូវឱ្យបង្ហាញជូននូវចម្លើយសាក្សីនានាកាលពីមុនៗមកនេះ គឺមានចែង *ក្នុងចំណោមវិធានដទៃៗទៀតជាច្រើន* នៅក្នុងវិធាន៧៦ នៃវិធានស្តីពីវិធាននិងភស្តុតាង (RoPE) របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ និងនៅក្នុងវិធាន៦៦ នៃ RoPE របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី។

[3] ឯកសារលេខ E127/4 អនុស្សរណៈដែលមានចំណងជើងថា “ការបង្ហាញជូននូវចម្លើយសាក្សីសំរាប់សាក្សីទាំងឡាយដែលអាចនឹងផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿងលេខ ០០២,” ចុះថ្ងៃទី២៤ មករា ២០១២។

[4] ឯកសារលេខ E127/6 អនុស្សរណៈដែលមានចំណងជើងថា “ការដាក់ចំណាត់ថ្នាក់ឡើងវិញទៅលើចម្លើយរបស់សាក្សីដែលអាចផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២,” ចុះថ្ងៃទី២៩ កុម្ភៈ ២០១២។